- សហការនិងសម្របសម្រួលជាមួយបណ្ដាក្រសួង ស្ថាប័ន អង្គទូត អង្គការជាតិនិងអង្គការអន្តរជាតិ សមាគមន៍នានា ដើម្បីរៀបចំខ្លឹមសារកិច្ចព្រមព្រៀងនិងគម្រោងស្នើសុំជំនួយដើម្បីអភិរក្សនិងអភិវឌ្ឍក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស ដែលផ្ដល់ជាគុណប្រយោជន៍ដល់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ព្រមទាំងបរិស្ថានជុំវិញ ដោយអនុលោមតាមគោលនយោបាយស្ដីពីកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រាជរដ្ឋាភិបាល
- សហការជាមួយរដ្ឋបាលខេត្តកំពង់ធំនិងស្ថាប័នពាក់ព័ន្ធ ទទួលបន្ទុកលើពិធីការនិងមគ្គុទ្ទេសក៍ទេសចរណ៍ជូនគណៈប្រតិភូជាតិនិងអន្តរជាតិសំខាន់ៗដែលអញ្ជើញមករមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំផែនការផ្សព្វផ្សាយអំពីរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក និងទំនាក់ទំនងជាមួយវិនិយោគិនផ្នែកឯកជនឱ្យចូលមកវិនិយោគក្នុងតំបន់រណប(តំបន់៣)
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុស្ដីពីចំណូលចំណាយរបស់ អ.ជ.ស.ព. ជូនប្រធាន អ.ជ.ស.ព. និងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ស្ដីពីសម្មភាពការងាររបស់អគ្គនាយកដ្ឋានតាមរយៈអគ្គនាយក អ.ជ.ស.ព. ជូនប្រធាន អ.ជ.ស.ព.
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

**មាត្រា៦ .-**

នាយកដ្ឋានសណ្ដាប់ធ្នាប់មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ការពារនិងថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- លើកផែនការនិងចាត់ចែងកងកម្លាំងការពារនៅតាមគោលដៅនានាដែលបានកំណត់
- អង្កេត តាមដាន និងទប់ស្កាត់សកម្មភាពល្មើសផ្សេងៗនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំឯកសារនិងបំពេញបែបបទផ្សេងៗដែលពាក់ព័ន្ធនឹងបទល្មើសក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកជូនអគ្គនាយក អ.ជ.ស.ព. ដើម្បីចាត់វិធានការតាមផ្លូវច្បាប់
- សហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់និងអង្គភាពពាក់ព័ន្ធ ដើម្បីមានវិធានការទប់ស្កាត់ចំពោះការសាងសង់ដែលគ្មានការអនុញ្ញាត ការកាប់បំផ្លាញព្រៃឈើ ការទន្ទ្រានយកដី ការគាស់រុករក ការលួចវត្ថុបុរាណ និងសកម្មភាពដែលបង្កឱ្យខូចខាតដល់រចនាសម្ព័ន្ធប្រាសាទនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ពាក់ព័ន្ធនឹងកិច្ចការពារសុវត្ថិភាពជូនភ្ញៀវទេសចរជាតិនិងអន្តរជាតិនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយក អ.ជ.ស.ព.
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

**មាត្រា៧ .-**

នាយកដ្ឋានរមណីយដ្ឋាន បុរាណវិទ្យា និងអភិរក្សមានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំផែនការមេស្តីពីការគ្រប់គ្រង អភិរក្ស និងថែទាំប្រាសាទក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដោយរួមបញ្ចូលនូវបញ្ជីស្តីពីស្ថានភាពប្រាសាទ ផែនទីចង្អុលកន្លែងគ្រោះថ្នាក់ និងស្ថានភាពនៃការអភិរក្សជាដើម
- រៀបចំកម្មវិធីនិងអនុវត្តការងារអភិរក្សប្រាសាទក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើការអង្កេតវាស់ស្ទង់និងធ្វើកំណាយបុរាណវិទ្យាក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ព្រមទាំងចាត់វិធានការបង្ការឬសង្គ្រោះស្ថានីយតាមការចាំបាច់
- ស្រាវជ្រាវបេតិកភណ្ឌរូបីនិងអរូបី ព្រមទាំងចងក្រងឡើងវិញនូវស្ថានភាពដើមរបស់ចម្លាក់និងរចនាសម្ព័ន្ធប្រាសាទ
- ត្រួតពិនិត្យនិងសម្របសម្រួលលើការដ្ឋានអន្តរជាតិនៃកម្មវិធីអភិរក្សប្រាសាទនិងបុរាណវិទ្យា
- ចុះបញ្ជីសារពើភណ្ឌប្រាសាទនិងគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រួមចំណែកក្នុងការធ្វើវិក្រឹតការឬបណ្តុះបណ្តាលបុគ្គលិកបច្ចេកទេស
- ផ្សព្វផ្សាយអំពីតម្លៃបេតិកភណ្ឌនៃរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកដល់ប្រជាពលរដ្ឋ
- កំណត់ទីតាំងសម្រាប់ការរៀបចំពិធីផ្សេងៗក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធនានា ក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងការលើកតម្លៃរមណីយដ្ឋាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយក អ.ជ.ស.ព.
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

**មាត្រា៨ .-**

នាយកដ្ឋានរៀបចំដែនដី លំនៅឋាន និងប្រជាសាស្ត្រមានតួនាទីនិងភារកិច្ចដូចតទៅ៖

- ពិនិត្យសំណើសុំសាងសង់និងរៀបចំលិខិតអនុញ្ញាតសាងសង់ ដោយត្រូវគោរពនូវតម្លៃបេតិកភណ្ឌនិងដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន ព្រមទាំងតាមដានពិនិត្យការសាងសង់
- សិក្សានិងកំណត់រចនាបថនៃសំណង់ដែលអាចអនុញ្ញាតឱ្យសាងសង់នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំបែបបទធ្វើបណ្ណកម្មសិទ្ធិប្រើប្រាស់ដីធ្លីឱ្យសមស្របជាមួយទិន្នន័យសុរិយោដី និងតាមបទប្បញ្ញត្តិជាធរមាន
- រៀបចំឯកសារស្តីពីដីធ្លីដែលស្ថិតនៅក្នុងគម្រោងរៀបចំអភិវឌ្ឍន៍រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំឱ្យមានមូលដ្ឋានទិន្នន័យប្រជាសាស្ត្រ ដើម្បីវិភាគ វាយតម្លៃ និងតាមដានការវិវត្តប្រជាសាស្ត្រក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- តាមដានការប្រែប្រួលកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកដើម្បីបង្កើនការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការស្តារ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានាក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- វិភាគនិងវាយតម្លៃអំពីផលប៉ះពាល់បណ្តាលមកពីគម្រោងវិនិយោគនិងអភិវឌ្ឍទាំងឡាយក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយក អ.ជ.ស.ព.

- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

**មាត្រា៩ .-**

នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍មានតួនាទីនិងភារកិច្ចដូចតទៅ៖

- កំណត់ទិសដៅនិងផែនការអភិវឌ្ឍទេសចរណ៍នៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធឱ្យស្របទៅនឹងគោលនយោបាយជាតិលើវិស័យទេសចរណ៍របស់រាជរដ្ឋាភិបាល
- ធ្វើស្ថិតិភ្ញៀវទេសចរដែលមកទស្សនារមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ក្នុងការរៀបចំនិងគ្រប់គ្រងការផ្តល់សេវាកម្មទេសចរណ៍នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- គ្រប់គ្រងពិធីនានាដែលរៀបចំនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ជំរុញផ្សព្វផ្សាយនិងសិក្សាទីផ្សារ ដើម្បីទាក់ទាញភ្ញៀវទេសចរមកទស្សនារមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សហការជាមួយដៃគូជាតិនិងអន្តរជាតិដែលមានជំនាញក្នុងវិស័យទេសចរណ៍
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ក្នុងការរៀបចំបណ្តុះបណ្តាល និងវិក្រឹតការមគ្គុទ្ទេសក៍ទេសចរណ៍សម្រាប់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំការត្រួតពិនិត្យជាប្រចាំលើគុណភាពសេវាកម្មទេសចរណ៍នៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយក អ.ជ.ស.ព.
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

**មាត្រា១០ .-**

នាយកដ្ឋានទេសភាពវប្បធម៌និងបរិស្ថានមានតួនាទីនិងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងសំណល់រឹង គ្រប់គ្រងទឹក ទាំងបរិមាណនៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- គ្រប់គ្រងព្រៃឈើនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក រួមមានការអភិរក្ស ការថែទាំ ការដាំកូនឈើឡើងវិញ និងការកំណត់អត្តសញ្ញាណដើមឈើ
- សិក្សាពីរុក្ខជាតិនិងសត្វនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ការពារនិងលើកតម្លៃទេសភាពវប្បធម៌និងធម្មជាតិដែលមានទំនាក់ទំនងនឹងប្រពៃណីប្រវត្តិសាស្ត្រខ្មែរ
- សិក្សានិងតាមដានព័ត៌មានទាក់ទងនឹងបម្រែបម្រួលអាកាសធាតុនៅតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ជូនអគ្គនាយក អ.ជ.ស.ព.
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ជូន។

## ជំពូកទី៥
## ការត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា១១.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ១(មួយ)រូប អមអគ្គនាយកដ្ឋាន អ.ជ.ស.ព. ដោយអនុលោមតាមអនុក្រឹត្យលេខ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាតាមក្រសួង អង្គភាពមូលដ្ឋានតាមបណ្តាលខេត្ត ក្រុង និងតាមអង្គភាពដែលមានឋានៈរដ្ឋបាល។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ប្រធានអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០. ខែ កញ្ញា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងជា**
**ប្រធានអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋាន**
**វប្បធម៌នៃប្រាសាទសំបូរព្រៃគុក**

**ភឿង សកុណា**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១១៧. អនក្រ.បក ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៥**

**ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក**

**អង្គការលេខរបស់អគ្គនាយកដ្ឋាន អ.ជ.ស.ព.**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១១៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតមន្ទីរសារការី សុក ស៊ីផាន់ណា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការី សុក ស៊ីផាន់ណា (SOK SIPHANA Notary Public)** នៃព្រះរាជាណាចក្រកម្ពុជា។

ត្រូវបានតែងតាំង លោក **សុក ស៊ីផាន់ណា** ជាសារការី ដើម្បីដឹកនាំមន្ទីរសារការី សុក ស៊ីផាន់ណា នេះ។

ក្នុងករណីចាំបាច់ មន្ទីរសារការី សុក ស៊ីផាន់ណា អាចធ្វើការជ្រើសរើសសារការីដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀតសម្រាប់ជួយបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបាន។

**មាត្រា ២.-**

មន្ទីរសារការី សុក ស៊ីផាន់ណា មានទីស្នាក់ការនៅអគារលេខ ៤៥អឺ១ ផ្លូវលេខ ៣៥៥ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ក្នុងករណីមានការផ្លាស់ប្តូរទីស្នាក់ការ មន្ទីរសារការីត្រូវជូនដំណឹងមកក្រសួងយុត្តិធម៌។

**មាត្រា ៣.-**

មន្ទីរសារការី សុក ស៊ីផាន់ណា មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបានយថា-ភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ធានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬចុះលេខាចារឹកទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកតោភាគីផ្សេងៗ មតកសាសន៍ និងលិខិតស្នាមគ្រប់ប្រភេទ
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត
- និងទទួលធ្វើកិច្ចការផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៤.-**

នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន មន្ទីរសារការី សុក ស៊ីផាន់ណា ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយមន្ទីរសារការី សុក ស៊ីផាន់ណា ប្រាក់តម្កល់ខាងលើនេះ ត្រូវបង្វិលជូនស្ថាបនិក បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងប្រាក់សោហ៊ុយនានា ដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ មន្ទីរសារការី សុក ស៊ីផាន់ណា និងសាមីខ្លួនដូចចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៦
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ...៧២៤ អនក្រ.បក...

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ៤៦ រូប ដែលបានបរិច្ចាគផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ សាលាឆាន់ ស្រះទឹក របងវត្ត រោងម៉ាស៊ីនភ្លើង ចាក់ដីបំពេញ ទីធ្លាវត្ត និងសមិទ្ធផលនានាជាច្រើនទៀត នៅ**វត្តកោសាលារាម** ស្ថិតនៅក្នុងឃុំគោកព្រីង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **ពៅ** | **ខែ** | ព្រះសង្ឃគង់នៅវត្តថាន់ | បច្ច័យចំនួន ១២.០០០ ដុល្លារ |
| ២-ឧបាសក | **មុំ** | **ឆន់** | អាចារ្យវត្តកោសាលារាម | ថវិកាចំនួន ១១.៥០០ ដុល្លារ |
| ៣-ឧបាសក | **រស់** | **ស៊ាម** | អាចារ្យវត្តកោសាលារាម | ថវិកាចំនួន ១១.៥០០ ដុល្លារ |
| ៤-ឧបាសក | **ពៅ** | **លីម** | អាចារ្យវត្តកោសាលារាម | ថវិកាចំនួន ១១.១០០ ដុល្លារ |
| ៥-លោក | **ខេង** | **សំអុល** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១១.០០០ ដុល្លារ |
| ៦-លោក | **អ៊ិន** | **ហ៊ួត** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១១.០០០ ដុល្លារ |
| ៧-លោក | **ប្រាក់** | **សារឿន** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១១.០៧០ ដុល្លារ |
| ៨-លោក | **ឈឹម** | **សឿន** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១១.០៥០ ដុល្លារ |

| | | | | |
|---|---|---|---|---|
| ៩-លោក | ពេញ | សាលី | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១១.០៥០ ដុល្លារ |
| ១០-លោក | មើក | ទិសុទ្ធ | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១១.០៥០ ដុល្លារ |
| ១១-លោក | ស្វួស | ប៊ិន | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១១.០២០ ដុល្លារ |
| ១២-លោក | សំ | សុផាត | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១១.០២០ ដុល្លារ |
| ១៣-លោក | ពុត | ខុន | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ១៤-ឧបាសក | សេក | ផេង | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.១០០ ដុល្លារ |
| ១៥-ឧបាសក | គល់ | ពុត | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០៣០ ដុល្លារ |
| ១៦-ឧបាសិកា | ស៊ូរ | ឆែត | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០៣០ ដុល្លារ |
| ១៧-ឧបាសិកា | ស៊ី | សារឿន | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០២០ ដុល្លារ |
| ១៨-លោកស្រី | ឆេព | សោមុន្នី | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០២០ ដុល្លារ |
| ១៩-ឧបាសិកា | ពៅ | ឈូក | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ២០-ឧបាសិកា | ខេង | សារឿន | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ២១-លោក | សេក | សុខុន | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ២២-លោកអាចារ្យ | ស | ឆយ | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ២៣-លោកអាចារ្យ | អ៊ុច | សារ៉ុន | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ២៤-លោក | យស់ | យុំ | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ២៥-លោក | ឡឹក | អុល | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ២៦-លោក | លឹម | សាវ៉ាន់ | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ២៧-លោក | ពៅ | ផល្លី | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ២៨-លោក | ម៉ិល | ធន | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ២៩-លោក | យស់ | ឃុល | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៣០-លោក | សេង | ចាន់ណា | សប្បុរសជននៅខេត្តបន្ទាយមានជ័យ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៣១-លោក | ហុង | សុផន | សប្បុរសជននៅខេត្តបន្ទាយមានជ័យ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៣២-លោក | អ៊ូច | ធឿន | សប្បុរសជននៅខេត្តបន្ទាយមានជ័យ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៣៣-លោក | តែ | វ៉ាន់ | សប្បុរសជននៅខេត្តបន្ទាយមានជ័យ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៣៤-លោក | រុន | ភារម្យ | សប្បុរសជននៅខេត្តបន្ទាយមានជ័យ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៣៥-លោក | កែវ | មនោរ៉ា | សប្បុរសជននៅខេត្តបន្ទាយមានជ័យ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៣៦-លោក | ចាប | ឈិត | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៣៧-លោក | គីម | សឿន | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |

| | | | | |
|---|---|---|---|---|
| ៣៨-លោក | **នាង** | **សាវឿន** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៣៩-លោក | **ម៉ែន** | **ហម** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៤០-លោក | **នុត** | **សាវ៉ុន** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៤១-លោក | **សោម** | **ឈឿង** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៤២-លោក | **ម៉ា** | **ឆុង** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៤៣-លោក | **រាជ** | **សំអឿន** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៤៤-លោក | **កែវ** | **សាំ** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៤៥-លោក | **សេក** | **សុខ** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៤៦-លោក | **ឆន់** | **ធីរះ** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |

មាត្រា ២ .—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី* ២៧ *ខែ* កក្កដា *ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល**</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...

# អនុក្រឹត្យ

## ស្ដីពី

## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៣៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **ជា ចាន់មុនី** អត្តលេខ ០៥៣៥៩ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៩៩ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១** : ផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ត្រី **ហ៊ុន ជា** អត្តលេខ ៥៥៥៥៥ ពីអនុប្រធាននាយកដ្ឋានចារកម្ម ទៅជាអនុប្រធាននាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌ ។

**មាត្រា២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួលៈ*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា          ជាតិ   សាសនា   ព្រះមហាក្សត្រ

លេខ: ៩០០ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់**វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ចំនួន ០២រូប នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម៖

១-លោកវរសេនីយ៍ទោ **នាង សុវណ្ណា**     អត្តលេខ ០៦០៥០

២-លោកវរសេនីយ៍ទោ **ប៉ូលី ដាស៊ី**     អត្តលេខ ៦៧០៧៩។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ[illegible] ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**...៩៧០១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ០៩ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តទីបាវសាន** ស្ថិតនៅក្នុងឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលមានរាយនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ០៤ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ **ឆិះ សៀវមិញ** | ព្រះចៅអធិការវត្តទីបាវសាន | បច្ច័យចំនួន ១១.៧០០ ដុល្លារ |
| ២-លោកស្រី **ទ៉េត ស្រីលីន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.២០០ ដុល្លារ |
| ៣-លោក **ជុំ សំអុល** | គណៈកម្មការវត្តទីបាវសាន | ថវិកាចំនួន ១០.៩០០ ដុល្លារ |
| ៤-ឧបាសក **គង់ ថេត** | អាចារ្យវត្តទីបាវសាន | ថវិកាចំនួន ១០.៣០០ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៥ គ្រឿង ផ្តល់ជូន :**

| | | |
|---|---|---|
| ១-ឧបាសិកា **អ៊ាង គីមហេង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៨.២០០ ដុល្លារ |
| ២-ឧបាសិកា **អ៊ុក យ៉ុន** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ៧.៥០០ ដុល្លារ |

| | | |
|---|---|---|
| ៣-ឧបាសិកា **ពិន ឈួន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៦.៣០០ ដុល្លារ |
| ៤-ឧបាសិកា **សួន ថុន** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ៥.៨០០ ដុល្លារ |
| ៥-ឧបាសិកា **កែវ ធឿន** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ៥.៥០០ ដុល្លារ |

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ [illegible] ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩០៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលឱ្យប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## សម្រេច

**មាត្រា១.**-បំពាក់ មេដាយសុវត្ថារា តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងសប្បុរសជន ចំនួន២៤រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ និងចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តមួយចំនួន របស់វិស័យឧស្សាហកម្ម និងសិប្បកម្ម កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ**

១-លោក សាំង លៀប នាយកក្រុមហ៊ុន អ៊ុយ ឡេង អារហ័ណនីរហ័ណ

២-លោក ឡូ ប៉ូយី ប្រធានសហគ្រាស ហួយ ម៉ិញប៉

៣-លោក វ៉ាន់ ម៉ៅ ប្រធាននាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ

៤-លោក ម៉េង សេរីរ៉ាត់ ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ

៥-លោក អ៊ុំ ពៅពិសី ប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ

៦-លោក សារិ ផល្លា អធិការ នៃអគ្គាធិការដ្ឋាន

៧-លោក នាក់ ជឿង អនុប្រធាននាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម

**ខ-មេដាយសុវត្ថារា ថ្នាក់សេនា**

១-លោក គេង វ៉ាន់ដារិទ្ធិ ប្រធានការិយាល័យ នៃមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា

២-លោក ខៀវ វិចិត្រ ប្រធានការិយាល័យ នៃនាយកដ្ឋានបញ្ញត្តកម្ម

៣-លោក ចឹក វិចិត្រ ប្រធានការិយាល័យ នៃនាយកដ្ឋានអគ្គិសនីស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់

៤-លោក សោម សាវ៉ាត អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រះសីហនុ

៥-លោក ចាន់ ជួន អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រះសីហនុ

៦-លោក សោរ វណ្ណា ប្រធានការិយាល័យ នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តតាកែវ
៧-លោក សុន ហួត ប្រធានការិយាល័យ នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពង់ស្ពឺ
៨-លោក សុក ស៊ីម ប្រធានការិយាល័យ នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពង់ស្ពឺ

**គ-មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ**

១-លោក ហួត ថានិន ប្រធានការិយាល័យ នៃនាយកដ្ឋានវិញ្ញាបនបត្រកម្ម
២-កញ្ញា ស៊ីដា រីយ៉ា មន្ត្រី នៃនាយកដ្ឋានព័ត៌មាន
៣-លោក ប៊ឹង សុខា អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រះសីហនុ
៤-លោក ផន រតនៈ ប្រធានការិយាល័យ នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រះសីហនុ
៥-លោកស្រី ហង់ ស៊ីថន ប្រធានការិយាល័យ នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តតាកែវ
៦-លោក ញ៉េវ សារ៉ែន ប្រធានការិយាល័យ នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តតាកែវ
៧-លោក ម៉ី ផល្លា ប្រធានការិយាល័យ នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តតាកែវ
៨-លោក យស វណ្ណស៊ីនី អនុប្រធានការិយាល័យ នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពង់ស្ពឺ
៩-លោក ពេជ្រ សំអូន ប្រធានការិយាល័យស្រុក នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពង់ស្ពឺ

**មាត្រា២.** .រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩០៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-** បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០៣រូប ដែលបានបរិច្ចាគថវិកាចំនួន ៥០.០០០ ដុល្លារអាមេរិក ជួយលាបថ្នាំអគារសិក្សា ចំនួន០១ខ្នង មាន១០បន្ទប់ សាងសង់បង្គន់អនាម័យ ១៣០បន្ទប់ រៀបចំបណ្ណាល័យ និងម៉ាស៊ីនបញ្ចាំងស្លាយ(LCD) ចំនួន០៥គ្រឿង និងសម្ភារនានាជាច្រើន ដូចមានរាយនាមខាងក្រោម ៖

១-លោក **យ៉ូន ប្យុង អឺន** Youn Byoung Eun AJU Corporation CEO (Chief executive officer)

២-លោក **មូ៉ន ក្យូ យ៉ុង** Moon Kyu Young AJU Welfare Foundation Representative Director

៣-លោក **លី ហ្គឺន ហ៊ី** Lee Guen Hee Director Of NGO Korea Foundation for World Aid Cambodia

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិថ្នាក់ វរសេនីយ៍ឯក នាយទាហាននៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោមៈ

១-វរសេនីយ៍ទោ **ជួប សុភណ្ឌ័** អត្តលេខ ០២២២៦៦ នាយរង ឧទ្ទកាល័យ កងទ័ពជើងគោក

២-វរសេនីយ៍ទោ **ភខ សុផល** អត្តលេខ ០០៨៩៧៤ នាយ ផ្នែកសរុប ឧទ្ទកាល័យ កងទ័ពជើងគោក

៣-វរសេនីយ៍ទោ **ជា សុចន្ថា** អត្តលេខ ០០៨៩៤៧ នាយផ្នែកហិរញ្ញវត្ថុ ឧទ្ទកាល័យ កងទ័ពជើងគោក

៤-វរសេនីយ៍ទោ **លី ចណ្ណាថា** អត្តលេខ ០០៨៩៦០ នាយ គិលានដ្ឋាន ឧទ្ទកាល័យ កងទ័ពជើងគោក

៥-វរសេនីយ៍ទោ **ទូច សារុន** អត្តលេខ ០២៧៦៨៣ នាយ ផ្នែកវិន័យទណ្ឌកម្ម ការិយាល័យទី១ កងទ័ពជើងគោក

៦-វរសេនីយ៍ទោ **ជ័យ សៅ** អត្តលេខ ០០៨៩៥១ នាយ ផ្នែកសន្តិសុខ ការិយាល័យទី១ កងទ័ពជើងគោក

៧-វរសេនីយ៍ទោ **ឈៀក សុខនី** អត្តលេខ ០១០២៣៥ នាយរងការិយាល័យទី២ កងទ័ពជើងគោក

៨-វរសេនីយ៍ទោ **ដួច មុន្នី** អត្តលេខ ០០៨៧៩១ នាយ ផ្នែកអប់រំវិន័យ ការិយាល័យទី២ កងទ័ពជើងគោក

៩-វរសេនីយ៍ទោ **ឡាំ គេច** អត្តលេខ ០១១៣៣២ នាយ ផ្នែកស៊ើបការណ៍ ការិយាល័យទី២ កងទ័ពជើងគោក

១០-វរសេនីយ៍ទោ **ស៊ីច ណារ៉ា** អត្តលេខ ០០៨៧៧៣ នាយផ្នែកវិទ្យុបច្ចេកទេស ការិយាល័យទី២ កងទ័ពជើងគោក

១១-វរសេនីយ៍ទោ **ឡុច វណ្ណះ** អត្តលេខ ០០៨៧៤៧ នាយ លេខាធិការដ្ឋាន ការិយាល័យទី២ កងទ័ពជើងគោក

១២-វរសេនីយ៍ទោ **គឹម សារ៉េត** អត្តលេខ ០១៦៦៧៦ នាយ ផ្នែកឯកសារបច្ចេកទេស ការិយាល័យទី២ កងទ័ពជើងគោក

១៣-វរសេនីយ៍ទោ **សូជី ទុន្សី** អត្តលេខ ០០១៩៤៦ នាយ ផ្នែកបូកសរុប ការិយាល័យទី៣ កងទ័ពជើងគោក

១៤-វរសេនីយ៍ទោ **សូ ស៊ីសំណួរ** អត្តលេខ ០០៤១៣៨ នាយផ្នែកប្រតិបត្តិការសឹក ការិយាល័យទី៣ កងទ័ពជើងគោក

១៥-វរសេនីយ៍ទោ **ច្រឹង សុន្ទរ៉ា** អត្តលេខ ០២៦៥០០ នាយរងការិយាល័យទី៥ កងទ័ពជើងគោក

១៦-វរសេនីយ៍ទោ **ស វណ្ណា** អត្តលេខ ០១៦៨៦៤ នាយរងការិយាល័យទី៥ កងទ័ពជើងគោក

១៧-វរសេនីយ៍ទោ **តន់ សូជា** អត្តលេខ ០០១៩៩៥ នាយ ផ្នែកទំនាក់ទំនងសាធារណៈ ការិយាល័យទី៥ កងទ័ពជើងគោក

១៨-វរសេនីយ៍ទោ **អ៊ុក សត្ថា** អត្តលេខ ០០៩៦០៣ នាយ ផ្នែកជំនាញចំរុះ ការិយាល័យហ្វឹកហ្វឺន កងទ័ពជើងគោក

១៩-វរសេនីយ៍ទោ **ទេព សាទី** អត្តលេខ ០១១៥៤៦ នាយ ផ្នែកឯកសារ ការិយាល័យហ្វឹកហ្វឺន កងទ័ពជើងគោក

២០-វរសេនីយ៍ទោ **ស៊ឹម វណ្ណះ** អត្តលេខ ០២៧៧០០ នាយ ផ្នែកសាលា ការិយាល័យហ្វឹកហ្វឺន កងទ័ពជើងគោក

២១-វរសេនីយ៍ទោ **ឈឿង សារិន** អត្តលេខ ០១៦៧៥៩ នាយ ផ្នែកហ្វឹកហ្វឺន ការិយាល័យហ្វឹកហ្វឺន កងទ័ពជើងគោក

២២-វរសេនីយ៍ទោ **ម៉ា សម្បត្តិ** អត្តលេខ ០៣៤១៥៥ នាយរងការិយាល័យយោធាតំបន់ កងទ័ពជើងគោក

២៣-វរសេនីយ៍ទោ **ឡុក សំអាត** អត្តលេខ ០១៦៧២២ នាយ ផ្នែកចិត្តសាស្ត្រប្រជាជន ការិយាលយយោធាតំបន់ កងទ័ពជើងគោក

២៤-វរសេនីយ៍ទោ **សេង សារិទ្ធ** អត្តលេខ ០១២៨២៩ នាយរងការិយាល័យការពារព្រំដែន កងទ័ពជើងគោក

២៥-វរសេនីយ៍ទោ **យ៉ា ធីទន្ត័** អត្តលេខ ០១២៨៩៤ នាយរងការិយាល័យការពារព្រំដែន កងទ័ពជើងគោក

២៦-វរសេនីយ៍ទោ **មាស សំបាន** អត្តលេខ ០២៣៩០៨ នាយរងការិយាល័យបច្ចេកទេស កងទ័ពជើងគោក

២៧-វរសេនីយ៍ទោ **សុខ សាទន** អត្តលេខ ០៨២២៣២ នាយផ្នែកសព្វាវុធ ការិយាល័យបច្ចេកទេស កងទ័ពជើងគោក

២៨-វរសេនីយ៍ទោ **សាន សុចិន្តា** អត្តលេខ ០១៧០៧២ នាយ ផ្នែកសំភារៈបច្ចេកទេស ការិយាល័យបច្ចេកទេស កងទ័ពជើងគោក

២៩-វរសេនីយ៍ទោ **ហែម សារី** អត្តលេខ ០២៦៨៩៧ មេបញ្ជាការរង បញ្ជាការដ្ឋានកាំភ្លើងធំ កងទ័ពជើងគោក

៣០-វរសេនីយ៍ទោ **ទៀប ហ៊ិត** អត្តលេខ ០៥០១១០ មេបញ្ជាការរង បញ្ជាការដ្ឋានកាំភ្លើងធំ កងទ័ពជើងគោក

៣១-វរសេនីយ៍ទោ **តាំង សារិទ្ធ** អត្តលេខ ០១០៧២៨ មេបញ្ជាការរង បញ្ជាការដ្ឋានកាំភ្លើងធំ កងទ័ពជើងគោក

៣២-វរសេនីយ៍ទោ **រ័ត្ន ទណ្ឌេត** អត្តលេខ ០១៧៤១៩ មេបញ្ជាការរង និងជានាយសេនាធិការ បញ្ជាការដ្ឋានកាំភ្លើងធំ កងជើងគោក

៣៣-វរសេនីយ៍ទោ **ឈាន គីមអាន** អត្តលេខ ០១០៦៥៩ មេបញ្ជាការរង បញ្ជាការដ្ឋានរថក្រោះ កងទ័ពជើងគោក

៣៤-វរសេនីយ៍ទោ **ស៊ុត សៅរ៉ាន់** អត្តលេខ ០០៣០៤២ មេបញ្ជាការរង បញ្ជាការដ្ឋានរថក្រោះ កងទ័ពជើងគោក

៣៥-វរសេនីយ៍ទោ **អ៊ឹង ម៉ុនរឿង** អត្តលេខ ០៤៤៩១១ មេបញ្ជាការរង បញ្ជាការដ្ឋានរថក្រោះ កងទ័ពជើងគោក

៣៦-វរសេនីយ៍ទោ **ចាន់ ម៉ូលី** អត្តលេខ ០០៩០៧១ មេបញ្ជាការរង បញ្ជាការដ្ឋានបញ្ជូនសារ កងទ័ពជើងគោក

៣៧-វរសេនីយ៍ទោ **គូ ទិត** អត្តលេខ ០០៩៣៤៨ ជំនួយការ ឯកឧត្តម យឿង សុខុន

៣៨-វរសេនីយ៍ទោ **ម៉ែន សារ៉ា** អត្តលេខ ០០៣០១០ នាយ ការិយាល័យអភិវឌ្ឍន៍ យោធភូមិភាគទី ៥

៣៩-វរសេនីយ៍ទោ **ផាយ សំរេច** អត្តលេខ ០១០៨៨៤ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ

៤០-វរសេនីយ៍ទោ **ជឹម ម៉ុនអាន** អត្តលេខ ០៣០២១៤ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ

៤១-វរសេនីយ៍ទោ **មាស ម៉េង** អត្តលេខ ០៣០១៥៩ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ

៤២-វរសេនីយ៍ទោ **ញឹល វណ្ណៈ** អត្តលេខ ០១២៤៩២ នាយករងសាលា កងរាជអាវុធហត្ថកំបូល បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៤៣-វរសេនីយ៍ទោ **ម៉េង ស្រ៊ុន** អត្តលេខ ១៦៧៥៣៨ មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ

៤៤-វរសេនីយ៍ទោ **ឈុំ សាឡឿន** អត្តលេខ ១១៣៤២៨ មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តត្បូងឃ្មុំ

៤៥-វរសេនីយ៍ទោ **អ៊ុយ សុឃាន** អត្តលេខ ០២០៤៨៥ មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកោះកុង

៤៦-វរសេនីយ៍ទោ **ទូន ឡុន** អត្តលេខ ០២០៦៨៦ មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តឧត្តរមានជ័យ

៤៧-វរសេនីយ៍ទោ **ធិន នីសុគន្ធា** អត្តលេខ ០១២៩៣៧ មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តឧត្តរមានជ័យ

៤៨-វរសេនីយ៍ទោ **ថូ សេង** អត្តលេខ ០៦២៨៦៧ មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ

៤៩-វរសេនីយ៍ទោ **មាស ហេងម៉េង** អត្តលេខ ០២០៦៣៧ មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកំពង់ឆ្នាំង

៥០-វរសេនីយ៍ទោ **ស ម៉ុនសឿង** អត្តលេខ ១៩៧៣៩២ មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ

៥១-វរសេនីយ៍ទោ **ឡុង ធិត្យ** អត្តលេខ ០៨៩៧៣៩ មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកំពង់ស្ពឺ

៥២-វរសេនីយ៍ទោ **ហ៊ុន សុភក្តិ** អត្តលេខ ០៣៥៧៨៣ មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តពោធិសាត់

៥៣-វរសេនីយ៍ទោ **ហោ ខេមម៉ាណូរ៉ា** អត្តលេខ ០១១៦០៣ ស្នងការរង ស្នងការដ្ឋានភស្តុភារ បច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៥៤-វរសេនីយ៍ទោ **មាន ស៊ីសុវណ្ណនី** អត្តលេខ ០៤៧២៣៤ ជំនួយការ ឯកឧត្តម មាស សភា

៥៥-វរសេនីយ៍ទោ **ប៉ាល់ ឃាន** អត្តលេខ ០៣៤៩៧៩ ជំនួយការ ឯកឧត្តម អ៊ុំ បុត្រ

៥៦-វរសេនីយ៍ទោ **អ៊ូ ស៊ិន** អត្តលេខ ០០៣១៧១ ជំនួយការ ឯកឧត្តម ម៉ៅ ផែន

៥៧-វរសេនីយ៍ទោ **ប្រាក់ សារ៉ាន្នី** អត្តលេខ ០១៧២៣៦ ជំនួយការ ឯកឧត្តម ម៉ាត់ ជាឡា

៥៨-វរសេនីយ៍ទោ **ជា ម៉ុនចាន់** អត្តលេខ ០៥៤៤៤៨ ជំនួយការ ឯកឧត្តម ខឹមជា សាខឿន

៥៩-វរសេនីយ៍ទោ **កុសល សុវណ្ណារតនៈ** អត្តលេខ ០១០០៣០ ជំនួយការ ឯកឧត្តម ឈិន ច័ន្ទពណ៌

៦០-វរសេនីយ៍ទោ **អ៊ិញ្ញ អ៊ា** អត្តលេខ ០០៨៧២៩ ជំនួយការ ឯកឧត្តម ព្រហ្ម មរណៈ

៦១-វរសេនីយ៍ទោ **សេង ធីម** អត្តលេខ ០២២២៧៤ ជំនួយការ ឯកឧត្តម មិន នីម

៦២-វរសេនីយ៍ទោ **ហាង ស្រេង** អត្តលេខ ១៣០៧៤០ ជំនួយការ មេបញ្ជាការរង កងទ័ពជើងគោក ប្រចាំទីបញ្ជាការសមរភូមិទិសយោធភូមិភាគទី៥

៦៣-វរសេនីយ៍ទោ **ហ៊ិន សារិន** អត្តលេខ ២៣១៦៦០ ជំនួយការ ឯកឧត្តម ញ៉ឹក ហួន

៦៤-វរសេនីយ៍ទោ **ជា ហៀង** អត្តលេខ ០៤៨៥៨១ ជំនួយការ ឯកឧត្តម ម៉ម សំ

៦៥-វរសេនីយ៍ទោ **អ៊ួន ស៊ឿន** អត្តលេខ ០២០៤២៦ ជំនួយការ ឯកឧត្តម គង់ វណ្ណី

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ៩/៧ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩០៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតម្លើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងព្រះរាជក្រឹត្យ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .-**

ត្រូវបានតម្លើងឋានន្តរស័ក្តិពី អនុមន្ត្រី ទៅ វរៈមន្ត្រី ក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការចំនួន ០២រូប ដូចមានរាយនាមខាងក្រោមៈ

១-លោកស្រី **ចំរើន សុខលួន** ពីអនុមន្ត្រីថ្នាក់លេខ ១ ទៅវរៈមន្ត្រីថ្នាក់លេខ ៣

២-លោកស្រី **ណា ស្រស់បញ្ញារ៉ា** ពីអនុមន្ត្រីថ្នាក់លេខ ២ ទៅវរៈមន្ត្រីថ្នាក់លេខ ៤

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួលៈ</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩០៧ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៥/០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២៣៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៤ ស្តីពីការកែតម្រូវមាត្រា១ និងមាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមសំណើរបស់ឯកឧត្តម **ញឹម វណ្ណដា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

**សម្រេច**

**មាត្រា ១ :** តែងតាំងមន្ត្រីរាជការ ចំនួន ០៣រូប ជានាយករងខុទ្ទកាល័យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដូចមានរាយនាមខាងក្រោម៖

១-លោក **ហួន ស៊ីន** មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

២-លោក **លន់ ទ្រព្យ** មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៣-លោក **សាំង ឌុត្តា** មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២:** តែងតាំងលោក **គីម សារ៉េត** ជាជំនួយការឯកឧត្តម **ញឹម វណ្ណដា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**..៩០៣..អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .-**

ត្រូវបានតែងតាំងលោក **អ៊ឹង ម៉ុនសុវណ្ណា** ឋានន្តរស័ក្តិ វរៈមន្ត្រី ថ្នាក់លេខ ៣ ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៩០៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យ លេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

**សម្រេច**

**មាត្រា ១:** តែងតាំងលោក **សេខ ឆូខ** ជាទីប្រឹក្សាអមក្រសួងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅ រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ៧ ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩០៩ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១ :** តែងតាំងទីប្រឹក្សាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០២ រូប បន្ថែមលើមុខងារបច្ចុប្បន្ន ដោយមិនយកប្រាក់បៀវត្សរ៍ ដូចមានរាយនាមខាងក្រោម ៖

១- លោកឧត្តមសេនីយ៍ត្រី **ស៊ូ ម៉ារ៉ាឌី** អត្តលេខ ០៣១០៥ មានឋានៈ**ស្មើប្រធាននាយកដ្ឋាន**

២- លោកឧត្តមសេនីយ៍ត្រី **ស ថេខ** អត្តលេខ ០១០៩៦ មានឋានៈ**ស្មើប្រធាននាយកដ្ឋាន** ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៩១០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា " **អាជ្ញាធរអប្សរា** "
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា " **អាជ្ញាធរអប្សរា** "
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលមាត្រា ៤ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា " **អាជ្ញាធរអប្សរា** "
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៦១៣ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលមាត្រា ៤ ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលមាត្រា ៤ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា " **អាជ្ញាធរអប្សរា** "

- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.-**

តែងតាំងលោក **ភ័ន ផល្លា** ជាប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក និងសម្ភារៈ នៃអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៩១១.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១ :** តែងតាំងមុខតំណែងលោកស្រីឧត្តមសេនីយ៍ទោ **គា ម៉ាន់លី** អត្តលេខ ០២១៣៧ ប្រធានលេខាធិការដ្ឋាន ទៅជាអគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល ។

**មាត្រា ២ :** បទប្បញ្ញត្តទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ [illegible] ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..៩.១៤.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដាក់អោយចូលនិវត្តន៍មន្ត្រីនគរបាលជាតកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/ ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញក្រឹត្យលេខ ១០ក្រ ចុះថ្ងៃទី ០៨ ខែកម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០០១ ស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៦១០ / ៤៦៤ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ។
- បានឃើញអនុក្រឹត្យលេខ១៦អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ដាក់អោយចូលនិវត្តន៍លោកស្រីវរសេនីយ៍ឯក **លី ចាន់ឌីណា** អត្តលេខ ០៥៦៦ នាយនគរបាលជាន់ខ្ពស់នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុង**មាត្រា១** ត្រូវអនុវត្ត អនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*<u>កន្លែងទទួល</u>*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាលកម្ពុជា*
- *ខុទ្ទការល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទការល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩១៣.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១** : ផ្ទេរក្របខ័ណ្ឌលោក **ឡាយ សុបញ្ញា** ពីឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងអប់រំ យុវជន និងកីឡា ទៅបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៦៧...សសរ.

# សេចក្តីសម្រេច

## ស្តីពី

## ការបំពេញបន្ថែមសមាជិកក្រុមជំនួយការនៃក្រុមការងារ ថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី នយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពី តួនាទី ភារកិច្ច និង របៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្មតាមមូលដ្ឋាន ដើម្បី ត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីសម្រេចលេខ២៩ សសរ ចុះថ្ងៃទី៣០/០៣/២០១៥ របស់រាជរដ្ឋាភិបាល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ ._**

ត្រូវបានបំពេញបន្ថែមសមាជិកក្រុមជំនួយការនៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្ត កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **អង មង្គល** | អនុរដ្ឋលេខាធិការ ក្រសួង មហាផ្ទៃ | **សមាជិក** |
| ២-ឯកឧត្តម | **ឌី សុភផាន** | អនុរដ្ឋលេខាធិការ ក្រសួង មហាផ្ទៃ | **សមាជិក** |

| | | | |
|---|---|---|---|
| ៣-ឯកឧត្តម | **ឱម សំអើល** | អនុរដ្ឋលេខាធិការ ក្រសួង អភិវឌ្ឍន៍ជនបទ | សមាជិក |
| ៤-ឯកឧត្តម | **កៅ ល្អប្រពៃ** | អនុរដ្ឋលេខាធិការ ក្រសួង រ៉ែ និង ថាមពល | សមាជិក |
| ៥-ឯកឧត្តម | **កើត មៀច** | អនុរដ្ឋលេខាធិការ ក្រសួង សុខាភិបាល | សមាជិក |
| ៦-ឯកឧត្តម | **សៅវណ្ណា សិរីវុឌ្ឍ** | អនុរដ្ឋលេខាធិការ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ៧-ឯកឧត្តម | **ម៉ៅ ឡាំង** | អនុរដ្ឋលេខាធិការ ក្រសួង សាធារណការនិង ដឹកជញ្ជូន | សមាជិក |
| ៨-លោកជំទាវ | **សួស រដ្ឋាវី** | អនុរដ្ឋលេខាធិការ ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩-ឯកឧត្តម | **ពេជ្រ វាសនា** | អគ្គលេខាធិការរង អាជ្ញាធរទន្លេសាប | សមាជិក |
| ១០-ឯកឧត្តម | **ម៉ែន ច័ន្ទសុខរិន** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ១១-ឯកឧត្តម | **ថោង មូរ៉ាន់** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួង អប់រំយុវជន និង កីឡា | សមាជិក |
| ១២-ឯកឧត្តម | **សេង ថានី** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ១៣-ឯកឧត្តម | **គីម សុភ:** | នាយកខុទ្ទកាល័យ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៤-ឯកឧត្តម | **អ៊ុំ សុថា** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ ក្រសួង ឧស្សាហកម្ម និង សិប្បកម្ម | សមាជិក |

១៥-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស៊ឹង ខាំចាន់តារ៉ុង** ប្រធានក្រុមស្រាវជ្រាវជំនាញប្រវត្តិសាស្ត្រ កងទ័ព ក្រសួងការពារជាតិ សមាជិក

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០១៥

តប. នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

**សម្តេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល</u>

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង-ស្ថាប័ន*
*-ប្រធានក្រុមការងារថ្នាក់ជាតិ ចុះរាជធានី ខេត្ត*
*-សាលារាជធានី ខេត្ត*
*-សាមីខ្លួនដូចមានចែងក្នុងប្រការ១*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៨ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការកែសម្រួលសមាជិកក្រុមការងារថ្នាក់ជាតិ**
**ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី**
**នយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.**_

ត្រូវបានកែសម្រួល សមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តមួយចំនួនដូចខាងក្រោម៖

១-ឯកឧត្តម **ខូវ មករា** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ពីសមាជិកក្រុមការងារខេត្តព្រះវិហារ មកជាសមាជិកក្រុមការងារខេត្តកណ្តាល

២-ឯកឧត្តម **សឿ ប៊ុនហ៊ីរ** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ក្រសួងកិច្ចការនារី ពីសមាជិកក្រុមការងារថ្នាក់ជាតិរាជធានីភ្នំពេញ មកជាសមាជិកក្រុមការងារខេត្តតាកែវ

៣-ឯកឧត្តម **គឹម បូរី** អគ្គនាយក នៃអគ្គនាយកដ្ឋានសាធារណការ ពីសមាជិកក្រុមការងារខេត្តកោះកុង មកជាសមាជិកក្រុមការងារខេត្តព្រៃវែង

៤-ឯកឧត្តម **ហៀក សុភាព** ទីប្រឹក្សាក្រសួងធម្មការ និង សាសនា ពីសមាជិកក្រុមការងារខេត្តកោះកុង មកជាសមាជិកក្រុមការងារខេត្តកំពង់ចាម

៥-ឯកឧត្តម **សាយ អំណាន** ទីប្រឹក្សាក្រសួងធម្មការ និងសាសនា ពីសមាជិកក្រុមការងារខេត្តកំពង់ចាម មកជាសមាជិកក្រុមការងារខេត្តកោះកុង

៦-ឯកឧត្តម **ប៉ូច ប៊ុណ្ណាក់** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានប្រជាជន និង ការអភិវឌ្ឍនៃក្រសួងផែនការ ពីសមាជិកក្រុមការងារខេត្តក្រចេះ មកជាសមាជិកក្រុមការងារខេត្តកំពង់ស្ពឺ

៧-លោក **ហ៊ីង លីហៃ** អគ្គនាយករង នៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ ជាសមាជិកក្រុមការងារខេត្តព្រះវិហារ

៨-លោក **ណុប ចន្ថារិទ្ធ** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងធម្មការ និង សាសនា ពីសមាជិកក្រុមការងារខេត្តកំពង់ចាម មកជាសមាជិកក្រុមការងារខេត្តកំពត

៩-ឯកឧត្តម **មុនី វីរៈ** អនុប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ ពីសមាជិកក្រុមការងារខេត្តឧត្តរមានជ័យ មកជាសមាជិកក្រុមការងារខេត្តបាត់ដំបង

១០-លោកឧត្តមសេនីយ៍ទោ **ព្រាប វុទ្ធី** សមាជិកក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ ពីសមាជិកក្រុមការងារខេត្តឧត្តរមានជ័យ មកជាសមាជិកក្រុមការងារខេត្តបាត់ដំបង

១១-លោក **កុច សុវ៉ាទ** អគ្គនាយករងបច្ចេកទេសក្រសួងបរិស្ថាន ពីសមាជិកក្រុមការងារថ្នាក់ជាតិខេត្តបាត់ដំបង មកជាសមាជិកក្រុមការងារខេត្តកោះកុង

**ប្រការ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្ត និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០១៥

**តប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**សម្ដេចក្រឡាហោម ស ខេង**

*__កន្លែងទទួល:__*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៧០ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី នយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅរាជធានី-ខេត្តដូចខាងក្រោម៖

១-ឯកឧត្តម **ប៊ី ហ៊ត់** អគ្គាធិការក្រសួងពាណិជ្ជកម្ម ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តសៀមរាប

២-លោកឧត្តមសេនីយ៍ទោ **មាស ថៃ** មេបញ្ជាការរងយោធភូមិភាគទី២ ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តក្រចេះ

៣-លោក **ហាម គឹមសុន** អគ្គនាយករងបេតិកភណ្ឌ នៃអគ្គនាយកដ្ឋានបេតិកភណ្ឌ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តស្វាយរៀង

៤-លោក **លឹម យុស្ធ** អគ្គនាយករងរដ្ឋបាល និង ហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តកំពត

៥-កញ្ញា **ជា ណារិន** អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តស្វាយរៀង

៦-លោក **គង់ បូលីន** អគ្គនាយករងបច្ចេកទេសវប្បធម៌ នៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តមណ្ឌលគិរី

៧-លោកស្រី **ម៉ែន ច័ន្ទទេវី** សាកលវិទ្យាធិការរង នៃស.ភ.វ.ស ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជាសមាជិកក្រុមការងារថ្នាក់ជាតិរាជធានីភ្នំពេញ

**ប្រការ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលរាជធានី-ខេត្ត និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០១៥

តប.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

សម្តេចក្រឡាហោម ស ខេង

*កន្លែងទទួល:*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:.....៧៧១...សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី នយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.**_

ត្រូវបានបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តមួយចំនួនដូចខាងក្រោម៖

១-ឯកឧត្តម **ញាណ សាធា** អនុរដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តស្ទឹងត្រែង

២-ឯកឧត្តម **កែវ ពង្ស** អនុរដ្ឋលេខធិការក្រសួងការពារជាតិ ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តកំពង់ស្ពឺ

៣-ឯកឧត្តម **ជុំ សុន្ទរី** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តតាកែវ

៤-ឯកឧត្តម **កាន់ ផារិទ្ធ** អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តកំពង់ឆ្នាំង

៥-ឯកឧត្តម **វ៉ាន សំអឿន** ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ជាសមាជិកក្រុមការងាថ្នាក់ជាតិខេត្តកំពត

៦-ឯកឧត្តម **កែវ ហុកលី** ទីប្រឹក្សារាជរដ្ឋាភិបាល ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តកំពត

៧-ឯកឧត្តម **ជូ ឈោង** ទីប្រឹក្សារាជរដ្ឋាភិបាល ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តកំពត

៨-ឯកឧត្តម **ថាំង ប៊ុនសុង** ទីប្រឹក្សារាជរដ្ឋាភិបាល ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តកំពត

៩-ឯកឧត្តម **អ៊ុក សោភ័ណ** អគ្គនាយក នៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេសនិងសហប្រតិ-បត្តិការអន្តរជាតិ ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តឧត្តរមានជ័យ

១០-ឯកឧត្តម **សាយ អំណាន** ទីប្រឹក្សាក្រសួងធម្មការនិងសាសនា ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តកោះកុង

១១-ឯកឧត្តម **ចាង យុនហ្សេង** ទីប្រឹក្សាក្រសួងធម្មការ និងសាសនា ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តកំពង់ចាម

១២-ឯកឧត្តម **ហុង ណាជ័ត** ទីប្រឹក្សាក្រសួងធម្មការ និងសាសនា ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តកំពង់ចាម

១៣-ឯកឧត្តម **ដេត ស៊ីដន** ទីប្រឹក្សាក្រសួងធម្មការ និងសាសនា ជាសមាជិកក្រុមការងារថ្នាក់ជាតិ

ខេត្តកំពង់ចាម

១៤-ឯកឧត្តម **នាក់ សំបូរ** ជំនួយការក្រសួងធម្មការ និងសាសនា ជាសមាជិកក្រុមការងារថ្នាក់ជាតិ ខេត្តកែប

១៥-លោក **សឿន សាន្ត** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យព្រះសុរាម្រឹត ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តឧត្តរមានជ័យ

១៦-លោកជំទាវ **ប៊ុនឈិត វាសនា** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជាសមាជិកក្រុមការងារថ្នាក់ជាតិ ខេត្តកណ្តាល

១៧-លោកជំទាវ **ឈោង ស៊ីថុន** ទីប្រឹក្សា ក្រសួងកិច្ចការនារី ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តត្បូងឃ្មុំ

១៨-លោកជំទាវ **ប៉ូអាន ស៊ីវុត្ថា** ទីប្រឹក្សា ក្រសួងកិច្ចការនារី ជាសមាជិកក្រុមការងារថ្នាក់ជាតិខេត្តស្ទឹងត្រែង

១៩-លោក **ម៉ី ហ៊ុល** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ក្រសួងកិច្ចការនារី ជាសមាជិកក្រុមការងារថ្នាក់ជាតិ ខេត្តរតនគិរី

២០-លោកស្រី **ឌី រ៉ានី** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ក្រសួងកិច្ចការនារី ជាសមាជិកក្រុមការងារថ្នាក់ជាតិ ខេត្តកំពង់ធំ

២១-លោកស្រី **ស៊ុន វណ្ណា** អគ្គនាយករង នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី ជាសមាជិកក្រុមការងារថ្នាក់ជាតិ រាជធានីភ្នំពេញ

២២-លោកស្រី **លឹម សុខន** អគ្គាធិការរង នៃអគ្គាធិការដ្ឋាន ក្រសួងកិច្ចការនារី ជាសមាជិកក្រុមការងារថ្នាក់ជាតិ ខេត្តបន្ទាយមានជ័យ

២៣-លោកស្រី **ឆាយ សន** អគ្គាធិការរង នៃអគ្គាធិការដ្ឋាន ក្រសួងកិច្ចការនារី ជាសមាជិកក្រុមការងារថ្នាក់ជាតិ ខេត្តកំពង់ស្ពឺ

២៤-លោកស្រី **ជូ សុខជានី** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងកិច្ចការនារី ជាសមាជិកក្រុមការងារក្រុមការងារថ្នាក់ជាតិ ខេត្តប៉ៃលិន

២៥-លោកស្រី **ចាន់ សុធារី** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជាសមាជិកក្រុមការងារថ្នាក់ជាតិ ខេត្តកណ្តាល

២៦-លោកស្រី **ម៉ែន សម្បត្តិ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជាសមាជិកក្រុមការងារថ្នាក់ជាតិ ខេត្តកណ្តាល

២៧-លោក **ស៊ិន វិសិទ្ធ** ប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្មនិងអភិរក្សនៃ អាជ្ញាធរ

ទន្លេសាបជាសមាជិកក្រុមការងារខេត្ត ព្រះវិហារ។

**ប្រការ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្ត និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០១៥

**តប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**សម្តេចក្រឡាហោម ស ខេង**

***កន្លែងទទួល:***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ........សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥

## ប្រកាស
## ស្តីពី
## ការបង្កើតក្រុមផ្តល់ប្រឹក្សាផ្នែកច្បាប់និងគោលនយោបាយ គម្រោងបញ្ជរតែមួយជាតិ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៤/០១៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមផ្តល់ប្រឹក្សាផ្នែកច្បាប់និងគោលនយោបាយគម្រោងបញ្ជរតែមួយជាតិ **"ក.ច.ប.ជ"** ដើម្បីបំពេញមុខងារជាសេនាធិការឲ្យគណៈកម្មការធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ លើបេសកកម្មរៀបចំកសាងច្បាប់និងបទប្បញ្ញត្តិ និងផ្តល់ប្រឹក្សាផ្នែកច្បាប់និងគោលនយោបាយ ពាក់ព័ន្ធនឹងបញ្ជរតែមួយជាតិ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១. ឯកឧត្តម **ប៉ែន សំអាត** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | ប្រធាន |
| ២. លោក **ខិម តារាឫទ្ធិ** | ប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣. លោក **ម៉ូរ ម៉ុនណារ៉ា** | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. ឯកឧត្តម **ជុន ម៉ាត** | អនុរដ្ឋលេខាធិការ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៥. លោក **គីមហាស សុខសីហា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកាំកុងត្រូល | សមាជិក |
| ៦. លោក **សុខ ស្រ៊ុន** | ប្រធាននាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល | សមាជិក |
| ៧. លោក **សរ សិនិរ៉ា** | ប្រធាននាយកដ្ឋាននីតិកម្ម និងច្បាប់វិនិយោគ នៃគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ៨. លោក **ចាត សូទីរៈ** | ប្រធាននាយកដ្ឋានបុគ្គលិក នៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៩. លោក **ស៊ាង ផល្លា** | អនុប្រធាននាយកដ្ឋាននីតិកម្ម នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១០. លោក **ទ៉ែន គៀមហាក់** | ប្រធាននាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១១. លោក **ស្រី ស៊ីណា** | អនុប្រធានក្តាប់រួមនៃនាយកដ្ឋាននីតិកម្មកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២. លោកស្រី **អេង គីមសួគ៌** | មន្ត្រីនាយកដ្ឋាននីតិកម្ម នៃក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៣. លោក **ពិត ច្រាកដ** | នាយក នៃនាយកដ្ឋានអាជីវកម្ម នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ | សមាជិក |
| ១៤. លោក **ហ៊ុន សុខាល័យ** | ប្រធានអង្គភាពតម្លៃ/ទីផ្សារ នៃកំពង់ផែស្វយ័តភ្នំពេញ | សមាជិក |

**ប្រការ ២.-**

**ក.ច.ប.ជ** មានតួនាទី និងភារកិច្ចដូចតទៅ ÷

42

- ពិនិត្យនិងផ្តល់អនុសាសន៍ លើច្បាប់និងបទប្បញ្ញត្តិ និងគោលនយោបាយពាក់ព័ន្ធនឹងការអភិវឌ្ឍ និងអនុវត្តគម្រោង តាមការស្នើរបស់គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ ឬ ក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ
- កសាងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ សម្រាប់គាំទ្រដល់ការអភិវឌ្ឍនិងអនុវត្តគម្រោង
- ធ្វើរបាយការណ៍វឌ្ឍនភាព ជូនគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការចាត់តាំងដោយប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ

**ប្រការ ៣.-**

ប្រកាស ឬសេចក្តីសម្រេចណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពនានានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គលពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន និងវិស័យឯកជន ពាក់ព័ន្ធ
- គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ “ដើម្បីជូនជ្រាប”
- ដូចប្រការ ៤ “ដើម្បីអនុវត្ត”
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ......សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥

## ប្រកាស
## ស្តីពី
## ការបង្កើតក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៤/០១៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ “**ភ.អ.ប.ជ**” ដើម្បីបំពេញមុខងារជាសេនាធិការឲ្យគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ លើបេសកកម្មរៀបចំនិងអភិវឌ្ឍមុខងារបច្ចេកទេស និងអនុវត្តគម្រោងបញ្ជរតែមួយជាតិ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១. លោក **ឡូន ច័ន្ទរិទ្ធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | ប្រធាន |
| ២. លោក **ផាន អូន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកាំកុងត្រូល | អនុប្រធាន |
| ៣. លោក **ផា អេងវ៉េង** | ប្រធាននាយកដ្ឋានរបបគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. លោកជំទាវ **ជា សិរី** | អគ្គនាយកបច្ចេកទេស នៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៥. លោក **ឆាង ម៉ៅ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៦. លោក **ហូ ស៊ីវយ៉ុង** | ប្រធាននាយកដ្ឋាននាំចេញ-នាំចូល នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧. លោក **ជា ថាវរក្ស** | ប្រធានការិយាល័យបញ្ញត្តិកម្មនៃនាយកដ្ឋានបញ្ញត្តិកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៨. លោក **ហេង ប៊ុនគៀត** | ប្រធាននាយកដ្ឋានឱសថ បរិក្ខារពេទ្យ ចំណីអាហារ និងគ្រឿងសំអាង នៃក្រសួងសុខាភិបាល | សមាជិក |
| ៩. លោក **យុន ហេង** | ប្រធាននាយកដ្ឋានវិភាគគម្រោង និងការលើកទឹកចិត្ត នៃគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ១០. លោក **នូច បូរី** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងព័ត៌មានវិទ្យា នៃក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១១. លោក **សួន សុធឿន** | អនុប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២. លោក **ថោង ទីរ៉ូ** | នាយក នៃនាយកដ្ឋាននាវាចរ-កណ្តធារ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ | សមាជិក |
| ១៣. លោក **ជាម សុផាន្នេរ** | ប្រធានអង្គភាពបច្ចេកវិទ្យា/ព័ត៌មានវិទ្យា នៃកំពង់ផែស្វយ័តភ្នំពេញ | សមាជិក |
| ១៤. លោក **ជួន ច័ន្ទសោភា** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៥. លោក **សុខ រតនា** | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៦. លោក **ប៊ូ សុធារិទ្ធ** | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៧. លោក **ណយ សុផាន់ណារិទ្ធ** | ភ្នាក់ងារគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |

១៨. លោក **សាន ចំរើន** ភ្នាក់ងារគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

១៩. លោក **ផាន់ តារិទ្ធ** ភ្នាក់ងារគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

២០. លោក **មឿន សុភក្តី** ភ្នាក់ងារគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

២១. លោក **វ៉ាន់ វុធថា** ភ្នាក់ងារគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

២២. លោក **មាស ឌីសត្យា** ភ្នាក់ងារគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

**ប្រការ ២.-**

**ក.អ.ប.ជ** មានតួនាទី និងភារកិច្ចដូចតទៅ ÷

- កសាងផែនការសកម្មភាព រៀបចំសមាសភាគបច្ចេកទេស និងផែនការថវិកាសម្រាប់ការអភិវឌ្ឍ និងអនុវត្តគម្រោង
- កសាងផែនការយុទ្ធសាស្ត្រទំនាក់ទំនងសម្រាប់ការអភិវឌ្ឍ និងអនុវត្តគម្រោង
- កសាងឯកសារលក្ខខណ្ឌការងារសម្រាប់ជ្រើសរើសអ្នកជំនាញបច្ចេកទេស ឬ ក្រុមហ៊ុន មកផ្តល់ប្រឹក្សាការងារអភិវឌ្ឍ និងអនុវត្តគម្រោង
- សម្របសម្រួល ទំនាក់ទំនង និងផ្តល់អនុសាសន៍ដល់ក្រុមការងារអភិវឌ្ឍនិងអនុវត្តគម្រោងប្រព័ន្ធស្វ័យប្រវត្តិកម្ម នៃក្រសួងស្ថាប័នជំនាញពាក់ព័ន្ធ សម្រាប់ការតភ្ជាប់មកប្រព័ន្ធបញ្ជរតែមួយជាតិ
- ស្វែងរកប្រភពថវិកានិងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានាសម្រាប់ការអភិវឌ្ឍ និងអនុវត្តគម្រោង
- ធ្វើរបាយការណ៍វឌ្ឍនភាពជូនគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការចាត់តាំងដោយប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ

**ប្រការ ៣.-**

ប្រកាស ឬសេចក្តីសម្រេចណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពនានានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គលពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន និងវិស័យឯកជន ពាក់ព័ន្ធ
- គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ “ដើម្បីជូនជ្រាប”
- ដូចប្រការ ៤ “ដើម្បីអនុវត្ត”
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៤៧៤...ឧស.កន.ស.ក.០៧

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ ផលិតទឹកដោះគោគ្រប់ប្រភេទ របស់ក្រុមហ៊ុន អង្គរ ឌែរី ប្រូដាក ខូអិលធីឌី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣។

## សម្រេច

